# កិច្ចប្រជុំគណៈកម្មាធិការដឹកនាំ
# គម្រោងប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្ម

នាថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានកិច្ចប្រជុំគណៈកម្មាធិការដឹកនាំគម្រោងលើកទី២ ស្តីពី **«គម្រោងប្រសិទ្ធភាពថាមពលក្នុងវិស័យឧស្សាហកម្ម»** ក្រោមអធិបតីភាព និងសម្របសម្រួលដោយ **ឯកឧត្តមបណ្ឌិត ទឹម ស៊ីនី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានស្តីទីគណៈកម្មាធិការដឹកនាំគម្រោង (ជំនួស **ឯកឧត្តម សាត សាមី** រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ) សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះមានតំណាងពីក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកៅស៊ូ ក្រសួងរ៉ែ និងថាមពល ប្រធានដាប៉ាតឺម៉ង់ទេពកោសល្យអគ្គិសនី និងថាមពលនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា សភាពាណិជ្ជកម្មកម្ពុជា សមាគមឧស្សាហកម្មតូច និងមធ្យមភ្នំពេញ ទីប្រឹក្សាបច្ចេកទេស ប្រធាន អនុប្រធាននិងសមាជិកសម្របសម្រួលគម្រោង របស់អង្គការUNIDO រួម ទាំង **ឯកឧត្តម សឹម ណារ៉ា** អគ្គនាយកឧស្សាហកម្ម **លោក វ៉ែន គៀហាក់** ប្រធាននាយកដ្ឋាន បច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា **លោក រាម ច័ន្ទវណ្ណា** ប្រធាននាយកដ្ឋាន សហគ្រាសធុនតូច និងមធ្យម របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

កិច្ចប្រជុំនេះរៀបចំឡើងក្នុងគោលបំណងដើម្បីពិនិត្យវាយតម្លៃលើសកម្មភាព លទ្ធផលការងារដែលបានអនុវត្តក្នុងរយៈពេល៦ខែកន្លងមក វិភាគរក ចំណុចខ្លាំង ចំណុចខ្សោយ ដំណោះស្រាយ និងពិនិត្យសម្រេចលើគម្រោងនានាពាក់ព័ន្ធនឹងប្រសិទ្ធភាពថាមពលក្នុងវិស័យឧស្សាហកម្ម ដែលត្រូវអនុវត្តបន្តសម្រាប់ឆ្នាំ២០១៥ ។ កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ១១: ៣០ នាទី នាថ្ងៃដដែល ប្រកបដោយការចូលរួមផ្តល់មតិយោបល់ និងការពិភាក្សាយ៉ាងសកម្មពីសមាជិកនៃអង្គប្រជុំទាំងមូល។

